**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**លេខ ១៩០ ប្រក កសក**


អគ្គនាយកដ្ឋានកៅស៊ូ
ចូល
លេខ... ៧២៧........
ថ្ងៃទី១៧.០៧.១៨ម៉ោង...
បញ្ជូន.........................


# ប្រកាស
## ស្តីពី
## នីតិវិធីនៃការគ្រប់គ្រងស្លាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលលេខ០៣ ប្រក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០០ ស្តីពីការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារនៅកម្ពុជា
- បានឃើញសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ១០ សរណន ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីវិធានការទប់ស្កាត់ការនាំចេញជ័រកៅស៊ូ និងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេស
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះមានគោលបំណងកំណត់នូវនីតិវិធីនៃការគ្រប់គ្រងស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារប្រកបដោយប្រសិទ្ធភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ ._**

ប្រកាសនេះមានគោលដៅ៖

- ធានាប្រសិទ្ធភាពគ្រប់គ្រងសកម្មភាពប្រមូលទិញជ័រកៅស៊ូគ្រួសារ
- លើកកម្ពស់ផលប្រយោជន៍សហគមន៍កៅស៊ូគ្រួសារ និងកសិករកៅស៊ូគ្រួសារ
- ពង្រឹងការអនុវត្តនីតិវិធីនៃការគ្រប់គ្រងសកម្មភាពប្រមូលទិញជ័រកៅស៊ូគ្រួសារ។

**ប្រការ៣ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពរបស់រូបវន្តបុគ្គលឬនីតិបុគ្គល ដែលពាក់ព័ន្ធការប្រមូលទិញជ័រកៅស៊ូគ្រួសារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ការគ្រប់គ្រងស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ

**ប្រការ៤ ._**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រកបរបរប្រមូលទិញជ័រកៅស៊ូគ្រួសារ ត្រូវសុំលិខិតអនុញ្ញាតបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារពីអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

រាល់សកម្មភាពប្រមូលទិញជ័រកៅស៊ូគ្រួសារ ត្រូវអនុវត្តនៅក្នុងស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារដែលបានអនុញ្ញាត និងកំណត់ទីតាំងដោយអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតែប៉ុណ្ណោះ។

**ប្រការ៥ ._**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ ត្រូវមានឯកសារណាមួយដូចខាងក្រោម៖

- ប្រកាសបង្កើតរោងចក្រឬសិប្បកម្មកែច្នៃជ័រកៅស៊ូ
- កិច្ចសន្យាជួលកែច្នៃពីរោងចក្រឬសិប្បកម្មកែច្នៃជ័រកៅស៊ូ
- លិខិតបញ្ជាក់ថាជាសាខារោងចក្រឬសិប្បកម្មកែច្នៃជ័រកៅស៊ូ។

**ប្រការ៦ ._**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ៖

- ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនៅអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ត្រូវបំពេញសំណុំឯកសារឱ្យបានត្រឹមត្រូវ តាមការកំណត់នៅក្នុងគំរូសំណុំបែបបទដូចមានក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំលិខិតអនុញ្ញាតបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ អាចទទួលលទ្ធផលនៃការសម្រេចរបស់អគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេលមិនលើសពី ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលពាក្យស្នើសុំជាផ្លូវការនៅអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ៧ ._**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

- លើកស្លាកសម្គាល់ "ស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ" និងដាក់បង្ហាញលិខិតអនុញ្ញាតក្នុងទីស្នាក់ការ ដែលបានអនុញ្ញាត
- បិទផ្សាយតារាងតម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារប្រចាំថ្ងៃ
- មិនត្រូវកៀបសង្កត់តម្លៃឬកេងបន្លំភាគកៅស៊ូស្ងួត (DRC: Dry Rubber Content) និងទម្ងន់ជ័រកៅស៊ូរបស់ម្ចាស់ចម្ការកៅស៊ូគ្រួសារ
- ធ្វើកំណត់ត្រាអំពីបរិមាណជ័រកៅស៊ូ ដែលប្រមូលទិញប្រចាំថ្ងៃ និងធ្វើរបាយការណ៍ប្រចាំខែមកអគ្គនាយកដ្ឋានកៅស៊ូឲ្យបានទៀងទាត់
- បង្កលក្ខណៈងាយស្រួលដល់ការបំពេញបេសកកម្មរបស់មន្ត្រីមានសមត្ថកិច្ចនៃអគ្គនាយកដ្ឋានកៅស៊ូ
- រក្សាសុវត្ថិភាពការងារ សុខភាព អនាម័យដល់កម្មករនិងនិយោជិត ការការពារបរិស្ថាន និងការទប់ស្កាត់ហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងក្នុងបរិវេណស្នាក់ការរបស់ខ្លួន
- អនុវត្តតាមលក្ខខណ្ឌផ្សេងទៀត ដែលតម្រូវដោយអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។

**ប្រការ៨ ._**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាតបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ ត្រូវមានកាតព្វកិច្ចបង់ពន្ធតាមគោលការណ៍ច្បាប់ជាធរមាន។

**ប្រការ៩ ._**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារដោយមិនអនុវត្តតាមប្រការ៧ នៃប្រកាសនេះ ត្រូវដកហូតលិខិតអនុញ្ញាតបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារដោយអគ្គនាយកដ្ឋាន-កៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

អគ្គនាយកដ្ឋានកៅស៊ូត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីបិទស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារដែលបានដកហូតលិខិតអនុញ្ញាតឬគ្មានលិខិតអនុញ្ញាតបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ។

## ជំពូកទី៣
## ការចរាចរនិងការលក់ដូរជ័រកៅស៊ូគ្រួសារ

**ប្រការ១០ ._**

ម្ចាស់ចម្ការកៅស៊ូគ្រួសារ មានសិទ្ធិចរាចរនិងលក់ជ័រកៅស៊ូ ដែលបានមកពីការប្រមូលផលលើដីចម្ការរបស់ខ្លួន ទៅឲ្យស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារស្របច្បាប់ណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១១ ._**

ការនាំចេញជ័រកៅស៊ូមិនទាន់កែច្នៃទៅបរទេសរួមមានៈ ទឹកជ័រ ជ័រកកគ្រប់ប្រភេទ និងកៅស៊ូសន្លឹកសំងួតនឹងខ្យល់ (USS: Unsmoked sheet) ត្រូវបានហាមឃាត់។

**ប្រការ១២ ._**

លិខិតអនុញ្ញាតបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារមានសុពលភាពរយៈពេល២(ពីរ)ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតអនុញ្ញាតលើកលែងតែមានការដកហូតដោយអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ១៣ ._**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាតបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ ត្រូវស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតបង្កើតស្នាក់ការរបស់ខ្លួនជាថ្មី នៅក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃមុនផុតសុពលភាព។ ក្នុងករណីខកខានក្នុងការស្នើសុំបន្តសុពលភាពជាថ្មី លិខិតអនុញ្ញាតបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារនោះ ត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិ។

រាល់ការផ្លាស់ប្តូរទីតាំងឬការផ្ទេរសិទ្ធិលើលិខិតអនុញ្ញាតបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ ត្រូវស្នើសុំលិខិតអនុញ្ញាតបង្កើតស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារជាថ្មីពីអគ្គនាយកដ្ឋានកៅស៊ូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ១៤ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៥ .–**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| ឧបសម្ព័ន្ធទី ១ |
|---|

## ពាក្យស្នើសុំបង្កើតស្ថានការប្រមូលទិញជ័រកៅស៊ូគ្រួសារ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.............................................អាយុ.................ឆ្នាំ...............ជនជាតិ.........
សញ្ជាតិ...............ទីលំនៅបច្ចុប្បន្នផ្ទះលេខ...............ក្រុម...................ភូមិ...............ឃុំ/សង្កាត់...........
ក្រុង/ស្រុក/ខណ្ឌ...................រាជធានី ខេត្ត...............ជា.............................................................។

**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ**

**កម្មវត្ថុ** : សំណើសុំលិខិតអនុញ្ញាតបង្កើតស្ថានការប្រមូលទិញជ័រកៅស៊ូគ្រួសារ។

**យោង** : ប្រកាសលេខ.........ប្រក.កសក ចុះថ្ងៃទី........ខែ...........ឆ្នាំ...........ស្តីពីនីតិវិធីនៃការគ្រប់គ្រងស្ថាន ការប្រមូលទិញជ័រកៅស៊ូគ្រួសារ។

**ជូនភ្ជាប់** : - វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម(ចំពោះក្រុមហ៊ុនពាណិជ្ជកម្ម) ...ចំនួន ០១ ច្បាប់
- ប្រកាសអនុញ្ញាតបង្កើតរោងចក្រកែច្នៃជ័រកៅស៊ូ(ចំពោះក្រុមហ៊ុនកែច្នៃជ័រកៅស៊ូ)...ចំនួន ០១ ច្បាប់
- ប័ណ្ណប៉ាតង់ប្រចាំឆ្នាំ២០១.... ...ចំនួន ០១ ច្បាប់
- កិច្ចសន្យាជួលកែច្នៃជ័រកៅស៊ូ(ក្នុងករណីបុគ្គលមិនមានរោងចក្រផ្ទាល់ខ្លួន) ...ចំនួន ០១ ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ យោង និងជូនភ្ជាប់ខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូនឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាមេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងស្នើសុំការអនុញ្ញាតដើម្បីបង្កើតស្ថានការប្រមូលទិញជ័រកៅស៊ូគ្រួសារដែលមានទីតាំងស្ថិតនៅចំណុចៈ

១/..........................................................................................................................។
២/..........................................................................................................................។
៣/..........................................................................................................................។

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាចំពោះឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាថាៈ

១- អនុវត្តតាមខ្លឹមសារនៃប្រកាសយោងខាងលើ។
២- ដាក់ស្ថានការប្រមូលទិញទៅតាមទីតាំងរបស់អគ្គនាយកដ្ឋានកៅស៊ូបានកំណត់។
៣- ប្រមូលទិញតែជ័រកៅស៊ូគ្រួសារ ដែលមានប្រភពច្បាស់លាស់។
៤- មិនធ្វើការកៀបសង្កត់ប្រជាពលរដ្ឋម្ចាស់ចម្ការកៅស៊ូគ្រួសារ ដោយប្រការណាមួយឡើយ។
៥- គោរពតាមការណែនាំរបស់អគ្គនាយកដ្ឋានកៅស៊ូ។
៦- រាយការណ៍ប្រចាំខែ តាមគំរូណែនាំជូនអគ្គនាយកដ្ឋានកៅស៊ូ។
៧- បង់ពន្ធគ្រប់ប្រភេទតាមការកំណត់របស់រដ្ឋ។
៨- ប្រសិនបើខ្ញុំបាទ/នាងខ្ញុំ ប្រព្រឹត្តខុសនឹងកិច្ចសន្យាខាងលើ ខ្ញុំបាទ/នាងខ្ញុំស្ម័គ្រចិត្តទទួលយកការដកហូតសិទ្ធិប្រមូលទិញ និងទទួលការផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូម ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា មេត្តាពិនិត្យនិងអនុញ្ញាតឲ្យខ្ញុំបាទ/នាងខ្ញុំបានបង្កើតស្ថានការប្រមូលទិញជ័រកៅស៊ូគ្រួសារ ដោយក្តីអនុគ្រោះ។

សូម ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ធ្វើនៅ.......................ថ្ងៃទី.................ខែ.............ឆ្នាំ២០១.....

**ហត្ថលេខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គំរូលិខិតអនុញ្ញាត**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកៅស៊ូ**

លេខ: អក.ជបស

# លិខិតអនុញ្ញាតបង្កើតស្ថាក់ការ ប្រមូលទិញជ័រកៅស៊ូគ្រួសារ

## អគ្គនាយកដ្ឋានកៅស៊ូ

- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្មនិងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០៣ ប្រក. ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០០ ស្តីពីការអភិវឌ្ឍដំណាំកៅស៊ូគ្រួសារនៅកម្ពុជា
- បានឃើញសារាចរណែនាំ របស់រាជរដ្ឋាភិបាលកម្ពុជាលេខ១០ សរណន ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីវិធានការទប់ស្កាត់ការនាំចេញជ័រកៅស៊ូ និងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេស
- បានឃើញប្រកាសលេខ......... ប្រក.កសក ចុះថ្ងៃទី... ខែ.... ឆ្នាំ..... ស្តីពីនីតិវិធីនៃការគ្រប់គ្រងស្ថាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ
- យោងតាមពាក្យស្នើសុំចុះថ្ងៃទី.....ខែ...... ឆ្នាំ២០១.... របស់.......................... ជាម្ចាស់សុំបង្កើតស្ថាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ

## អ នុ ញ្ញា ត

ឲ្យលោក/លោកស្រី .......................... អាយុ......... ឆ្នាំ ជនជាតិ...... សញ្ជាតិ......... អាសយដ្ឋានបច្ចុប្បន្នផ្ទះ: .................. ឃុំ/សង្កាត់ ..................ក្រុង/ស្រុក/ខណ្ឌ.................. រាជធានី ខេត្ត ............... កាន់អត្តសញ្ញាណប័ណ្ណលេខ........................... បង្កើតស្ថាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ ដែលមានទីតាំងស្ថិតនៅភូមិ ........... ឃុំ/សង្កាត់ .......... ក្រុង/ស្រុក/ខណ្ឌ............ រាជធានី ខេត្ត ................ ។

លោក/លោកស្រី.................... ត្រូវអនុវត្តការងារប្រមូលទិញនិងចរាចរជ័រកៅស៊ូគ្រួសារទៅតាមកិច្ចសន្យារបស់ខ្លួន ដោយគោរពតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

លិខិតអនុញ្ញាតនេះមានសុពលភាពប្រើប្រាស់សម្រាប់រយៈពេល ២(ពីរ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់ថ្ងៃទី .... ខែ ..... ឆ្នាំ២០១.. ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១*

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ**

**ច្បាប់ដើម**